## ៤. ការវាយតម្លៃចុងក្រោយសម្រាប់វគ្គបណ្តុះបណ្តាល

| | |
|---|---|
| សេចក្តីពណ៌នា | នេះគឺជាការវាយតម្លៃចុងក្រោយ ដែលត្រូវធ្វើឡើងនៅថ្ងៃបញ្ចប់នៃវគ្គបណ្តុះបណ្តាល ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃដោយការចូលរួម។ |
| គោលបំណង | ការវាយតម្លៃនេះមានបំណងផ្តល់មតិកែលម្អដល់គ្រូបង្គោល អំពីវគ្គបណ្តុះបណ្តាល និងវាស់ស្ទង់មើលបទពិសោធន៍រៀនរបស់អ្នកចូលរួម។ ការវាយតម្លៃនេះផ្តល់ឱកាសឲ្យអ្នកចូលរួមលើកឡើងពី ចំនុចខ្លាំង និងចំនុចខ្សោយរបស់វគ្គបណ្តុះបណ្តាល។ |
| ពេលវេលា | ៣០នាទី |
| សម្ភារៈ | ក្រដាសផ្ទាំងធំ ប័ណ្ណពណ៌ចំនួនបី និងប៊ិចហ្វឺតខ្មៅសម្រាប់អ្នកចូលរួម ស្កុតបិត/កាវ សម្រាប់បិតប័ណ្ណនៅលើក្រដាសផ្ទាំងធំ។ |
| វិធី | គូសតារាងមួយទុក (សូមមើលឧទាហរណ៍ខាងក្រោម) រួចគូររូបមុខ សម្រាប់ផ្តល់ពិន្ទុ (មុខញញឹម មុខពិបាកចិត្ត មុខធ្វល់)។<br><br>ផ្តល់ប័ណ្ណពណ៌ចំនួន៣ (បៃតង ក្រហម និងលឿង)ទៅឱ្យអ្នកចូលរួមម្នាក់ៗ និងសុំឲ្យពួកគាត់សរសេរដោយខ្លួនឯងនូវចំនុចខាងក្រោម (ប័ណ្ណមួយសរសេរមួយឃ្លា)៖<br><br>» សរសេរចំនុចមួយដែលខ្ញុំចូលចិត្តលើប័ណ្ណបៃតង–វិជ្ជមាន ☺<br>» សរសេរចំនុចមួយដែលខ្ញុំមិនចូលចិត្តលើប័ណ្ណក្រហម–អវិជ្ជមាន ☹<br>» សរសេរចំនុចមួយដែលខ្ញុំមិនទាន់យល់ច្បាស់ លើប័ណ្ណលឿង–មិនប្រាកដ 😐<br><br>បន្ទាប់មក ប្រមូលប័ណ្ណទាំងអស់ អានលឺៗ និងរៀបទៅតាមប្រធានបទ៖ មតិយោបល់ទូទៅ ខ្លឹមសារមេរៀន ការបង្រៀននិងការសម្របសម្រួល និងបទពិសោធន៍ពេលរៀន។<br><br>សរុប និងសង្ខេបឡើងវិញនូវមតិយោបល់អ្នកចូលរួម។ |

| | |
|---|---|
| ឧទាហរណ៍នៃសំណួរបំផុសគំនិត និងប្រធានបទ | ប្រសិនបើអ្នកចូលរួមមិនដឹងថាត្រូវសរសេរមតិយោបល់អ្វី អ្នកអាចប្រើសំណួរខាងក្រោមដើម្បីសួរពួកគាត់៖<br><br>មតិយោបល់ទូទៅ<br>» អ្នកគិតយ៉ាងម៉េចដែរចំពោះវគ្គបណ្តុះបណ្តាលនេះ?<br>» តើការរៀបចំវគ្គបណ្តុះបណ្តាលនេះបានល្អយ៉ាងណាដែរ?<br><br>ខ្លឹមសារមេរៀន<br>» តើវគ្គបណ្តុះបណ្តាលនេះសំរេចគោលដៅ/គោលបំណងរបស់វគ្គទេ?<br>» តើមានខ្លឹមសារប៉ុន្មានដែលថ្មីសម្រាប់អ្នក?<br>» តើធ្វើដូម្តេចដើម្បីជួយឲ្យការរៀបចំពេលវេលា ខ្លឹមសារ និងរចនាសម្ព័ន្ធមេរៀនបានប្រសើរឡើង?<br>» តើឯកសារមេរៀនងាយយល់ទេ?<br><br>ការបង្រៀន និងការសម្របសម្រួល<br>» តើគ្រូបង្រៀនមានប្រសិទ្ធិភាពទេ?<br><br>បទពិសោធន៍ពេលរៀន (អ្វីដែលអ្នកទទួលបាន/មិនបាន)<br>» តើវគ្គនេះផ្តល់ព័ត៌មានពាក់ព័ន្ធជាមួយតម្រូវការរបស់អ្នកទេ?<br>» តើវគ្គនេះបានជម្រុញទឹកចិត្តអ្នកយ៉ាងណាដែរ?<br>» តើការអនុវត្តនៅមូលដ្ឋានមានប្រយោជន៍សម្រាប់អ្នកទេ?<br><br>ធ្វើការសម្របសម្រួល និងបែងចែកចម្លើយទៅតាមប្រធានបទ។ |

| | វិជ្ជមាន ☺ | មិនប្រាកដ 😐 | អវិជ្ជមាន ☹ |
|---|---|---|---|
| មតិយោបល់ទូទៅ | | | |
| ខ្លឹមសារមេរៀន | | | |
| ការបង្រៀន និងការសម្របសម្រួល | | | |
| បទពិសោធន៍ពេលរៀន | | | |